


# 2025 របាយការណ៍ប្រចាំត្រីមាសទី២

ក្រុមហ៊ុន ខេម ជីអេសអេម ម.ក

cellcard
ROYAL GROUP
SINCE 1991

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | | ត្រីមាសទី២ ឆ្នាំ២០២៥ (បានត្រួតពិនិត្យ) | ឆ្នាំ២០២៤ (បានធ្វើសវនកម្ម) |
|---|---|---|---|
| ទ្រព្យសកម្មសរុប | | ២.៦៤៥.៤៣៥ | ២.៦៥៤.៩៦២ |
| បំណុលសរុប | | ១.៤៣៤.០៣៩ | ១.៤៥៧.០៨១ |
| មូលធនសរុប | | ១.២១១.៣៩៦ | ១.១៩៧.៨៨១ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | | **ត្រីមាសទី២ ឆ្នាំ២០២៥ (បានត្រួតពិនិត្យ)** | **ត្រីមាសទី២ ឆ្នាំ២០២៤ (បានត្រួតពិនិត្យ)** |
| ចំណូលសរុប | | ១៧៣.២៨៣ | ១៧៨.៦៣៥ |
| ចំណេញ/(ខាត) មុនពន្ធលើប្រាក់ចំណូល | | ១៨.០៤០ | ២៣.៤៩៥ |
| ចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ | | ១៤.៩៣៣ | ១៨.៣៣១ |
| លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ | | ១៤.៩៥២ | ១៨.៤៦៦ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី២ ឆ្នាំ២០២៥ (បានត្រួតពិនិត្យ)** | **ឆ្នាំ២០២៤ (បានធ្វើសវនកម្ម)** |
| អនុបាតសាធនភាព (ដង) | | ០,៤៦ | ០,៤៥ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត (%) | ៣២៤% | ៣៣៧% |
| | អនុបាតចរន្តលឿន (%) | ២១% | ៣២% |
| | | **ត្រីមាសទី២ ឆ្នាំ២០២៥ (បានត្រួតពិនិត្យ)** | **ត្រីមាសទី២ ឆ្នាំ២០២៤ (បានត្រួតពិនិត្យ)** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (%) | ១% | ១% |
| | អនុបាតចំណេញធៀបនឹងមូលធន (%) | ១% | ១% |
| | អនុបាតគម្លាតចំណេញដុល(%) | ៧២% | ៧៧% |
| | អនុបាតគម្លាតចំណេញភាព(%) | ៩% | ១០% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៨ | ៩ |
| អនុបាតលទ្ធភាពសងការប្រាក់ (ដង) | | ៤ | ៤ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ស្ថានភាពហិរញ្ញវត្ថុ










**ទ្រព្យសកម្មសរុប៖**
ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានថយចុះចំនួន០,៤% ឬ ១០ ប៊ីលានរៀល ធៀបនឹងឆ្នាំ២០២៤។

**បំណុលសរុប៖**
ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានថយចុះចំនួន២% ឬ២៣ ប៊ីលានរៀល ធៀបនឹងឆ្នាំ២០២៤។

**មូលធនសរុប៖**
ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានកើនឡើងចំនួន ១% ឬ ១៣ ប៊ីលានរៀល ធៀបនឹងឆ្នាំ ២០២៤។

## លទ្ធផលចំណូលលម្អិត
## ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗ













**ចំណូលសរុប**

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានថយចុះចំនួន ៣% ឬ ៦ ប៊ីលានរៀល ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤។

**ចំណេញ/(ខាត) មុនពន្ធលើប្រាក់ចំណូល**

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានថយចុះចំនួន ២២% ឬ ៥ ប៊ីលានរៀល ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤។

**ចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ**

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានថយចុះចំនួន ១៧% ឬ ៣ ប៊ីលានរៀល ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤។

**លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ**

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ បានថយចុះចំនួន ១៧% ឬ ៣ ប៊ីលានរៀល ធៀបនឹងត្រីមាសទី២ ឆ្នាំ ២០២៤។

# BOARD OF DIRECTORS



NEAK OKNHA KITH MENG
CHAIRMAN



MR. WILLIAM MARK HANNA
NON-EXECUTIVE DIRECTOR



MR. PAUL CAREY CLEMENTS
NON-EXECUTIVE DIRECTOR



MR. CHRISTOPHER DONALD TIFFIN
NON-EXECUTIVE DIRECTOR



MS. HEP SEKA
INDEPENDENT DIRECTOR

# សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញលទ្ធផលការងារប្រចាំត្រីមាសទីពីរនៃឆ្នាំ ២០២៥ របស់ ក្រុមហ៊ុន ខេម ជីអេសអេម ម.ក។ លទ្ធផលប្រចាំត្រីមាសនេះ បានឆ្លុះបញ្ចាំងពីសក្តានុពល ស្ថេរភាព ភាពរីកចម្រើន និងបន្តប្តេជ្ញាក្នុងការផ្តល់នូវសេវាកម្មដែលមានគុណភាពខ្ពស់ដល់ប្រជាពលរដ្ឋកម្ពុជា។

ក្នុងត្រីមាសនេះ ក្រុមហ៊ុន ខេម ជីអេសអេម ម.ក នៅបន្តដំណើរការប្រកបដោយស្ថេរភាព ទោះបីជាមានការប្រកួតប្រជែងតានតឹង និងរងការជះឥទ្ធិពលពីបញ្ហាក្នុងតំបន់ក៏ដោយ។ សេវាទូរស័ព្ទ និងបណ្តាញសេវារបស់ក្រុមហ៊ុននៅតែបន្តរីកចម្រើនពីមួយត្រីមាសទៅមួយត្រីមាស ដើម្បីសម្របតាមតម្រូវការរបស់អតិថិជនក្នុងការភ្ជាប់អ៊ីនធឺណិតល្បឿនលឿន និងផ្តល់ទំនុកចិត្តខ្ពស់។ ក្រុមហ៊ុនបានពង្រីកសមត្ថភាពបណ្តាញអ៊ីនធឺណិត បង្កើនគុណភាពសេវា4G នៅក្នុងតំបន់សំខាន់ៗ និងបានបន្ថែមនូវសេវាកម្មថ្មីៗដែលបានជំរុញនូវកំណើនអ្នកប្រើប្រាស់ និងទំនុកចិត្តសម្រាប់អតិថិជន។

ជាមួយនឹងគ្នានេះដែរ ក្នុងកាលៈទេសៈមួយដែលបានសាកល្បងពីភាពរឹងមាំនៃវិស័យទូរគមនាគមន៍របស់ប្រទេសកម្ពុជា ជាពិសេសក្រុមហ៊ុន ខេម ជីអេសអេម នោះគឺក្រុមហ៊ុនបានផ្តាច់ការភ្ជាប់បណ្តាញអ៊ីនធឺណិតពីប្រទេសថៃនាខែមិថុនា ឆ្នាំ២០២៥។ បើទោះជាស្ថិតក្នុងស្ថានភាពឥតព្រៀងទុកនេះក្តី ក្រុមហ៊ុនបានឆ្លើយតបនូវបញ្ហានោះវិញបានយ៉ាងរហ័ស និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្រោមកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងការផ្លាស់ប្តូរទិសដៅ IP Transit អន្តរជាតិទៅទីតាំងផ្សេង ក្រុមហ៊ុននៅបន្តរក្សាការផ្គត់ផ្គង់សេវាអ៊ីនធឺណិតសម្រាប់អតិថិជនទូទាំងប្រទេសដោយពុំមានការបង្អាក់បណ្តាញសេវា។ ដោយមានក្រុមការងារបច្ចេកទេស ស្របជាមួយនឹងសហការក្នុងការដោះស្រាយនូវការតភ្ជាប់បណ្តាញអ៊ីនធឺណិតបានឆាប់រហ័ស បានបង្ហាញពីសមត្ថភាពរបស់ក្រុមហ៊ុនក្នុងស្ថានភាពដ៏តានតឹងក្នុងស្រុកនេះ។

ក្នុងត្រីមាសនេះ ក្រុមហ៊ុនបានដាក់ចេញនូវសេវាកម្មថ្មីៗជាច្រើនដូចជា ស៊ីមយុគ៩ និង Data SIM ដែលទទួលបានការគាំទ្រយ៉ាងច្រើនសន្ធឹកសន្ធាប់ពីសំណាក់អតិថិជន។ ក្រុមហ៊ុនក៏បានផ្តល់នូវសេវាកម្មបន្ថែមដូចជា ការបន្តសុពលភាពកញ្ចប់រ៉ូមីង ការដាក់ដំណើរការកញ្ចប់ MLBB និងកញ្ចប់អ៊ីនធឺណិតរៀនបន្ថែម និងកញ្ចប់សេវាផ្សេងៗមួយចំនួនទៀត។

នាត្រីមាសបន្ទាប់ ក្រុមហ៊ុននៅតែប្រកាន់គោលជំហរច្បាស់លាស់ក្នុងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ការផ្តល់នូវការតភ្ជាប់អ៊ីនធឺណិតរហ័ស និងការគាំទ្រចក្ខុវិស័យរបស់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍ប្រព័ន្ធឌីជីថល។ ជាមួយនឹងសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការសម្របខ្លួននឹងបញ្ហាប្រឈម ស្របជាមួយនឹងការបន្តការអភិវឌ្ឍន៍ឥតងាករេ ក្រុមហ៊ុនជឿជាក់យ៉ាងមុតមាំថា ក្រុមហ៊ុបានត្រៀមខ្លួនរួចជាស្រេចក្នុងការដោះស្រាយរាល់បញ្ហាប្រឈមនាពេលខាងមុខ។

ក្នុងនាមក្រុមប្រឹក្សាភិបាលទាំងអស់ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន បុគ្គលិក និងភាគហ៊ុនិកទាំងអស់ ចំពោះការបន្តជឿជាក់ និងការគាំទ្រមកកាន់ក្រុមហ៊ុន។

ដោយក្តីគោរពអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥




អ្នកឧកញ៉ា គិត ម៉េង
ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប.......... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប .......... ii

លទ្ធផលចំណូលលម្អិតចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ .......... ivii

សមាសភាពក្រុមប្រឹក្សាភិបាល.......... iv

សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល.......... v

ផ្នែកទី ១៖ ព័ត៌មានទូទៅរបស់ក្រុមហ៊ុនចុះបញ្ជី .......... ១

ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី.......... ១

ខ. លក្ខណៈនៃធុរកិច្ច .......... ១

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាស .......... ៣

ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច .......... ៧

ក. លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក.......... ៧

ខ. រចនាសម្ព័ន្ធនៃចំណូលក្រុមហ៊ុន .......... ៨

ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ.......... ៨

ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង.......... ៩

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ .......... ៩

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ.......... ១២

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល .......... ១៣

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ.......... ១៣

ង. ផលប៉ះពាល់នៃអតិផរណា .......... ១៣

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល.......... ១៣

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល ៣ខែ បញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥.......... ១៦

## ផ្នែកទី ១៖ ព័ត៌មានទូទៅរបស់ក្រុមហ៊ុនចុះបញ្ជី

### ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ក្រុមហ៊ុន ខេម ជីអេសអេម ម.ក |
| ជាអក្សរឡាតាំង | CAMGSM PLC. |
| អក្សរកូដ | KH១០០០០២២០០០៩ |
| ទីស្នាក់ការ | ផ្ទះលេខ ២៤៦ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +(៨៥៥) ១២ ៨១២ ៨១២/៨១២ |
| លេខទូរសារ | គ្មាន |
| គេហទំព័រ | www.cellcard.com.kh |
| អ៊ីម៉ែល | investor_relations@cellcard.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥២៧៤ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណ | គ្មាន |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦១/២៣ SERC/SSR ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ ដោយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) |
| ឈ្មោះបុគ្គលតំណាងក្រុមហ៊ុន | **លោក Yap Kok Leong** |

### ខ. លក្ខណៈនៃធុរកិច្ច

ក្រុមហ៊ុន ខេម ជីអេសអេម ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលក្រុមហ៊ុនកាន់កាប់ (ត្រូវហៅជារួមថា"សម្ព័ន្ធ") គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក ស្ថិតនៅអគារលេខ ២៤៦ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានទទួលលិខិតអនុម័តវិនិយោគលេខ ១០៦៦/៩៦ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាវិនិយោគកម្ពុជាចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៦។ ក្រុមហ៊ុនបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម និងបានទទួលលិខិតយោងលេខ២១៥៩ ព.ណ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៦។ វិញ្ញាបនបត្រចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មលេខ ០០០១៥២៧៤។

ក្រុមហ៊ុនត្រូវបានកាន់កាប់ភាគច្រើនដោយក្រុមហ៊ុន រ៉ូយ៉ាល់ មីលីខម ("RMC") ដែលមានការិយាល័យកណ្តាលស្ថិតនៅផ្ទះលេខ ២៤៦ H-I មហាវិថី ព្រះមុនីវង្ស រាជធានីភ្នំពេញ។ RMC គឺជាក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម រវាងក្រុមហ៊ុន Three Star Investment Cambodia Ltd., ជាក្រុមហ៊ុន ដែលបានចុះបញ្ជីនៅ Cayman Islands ដែលមានភាគហ៊ុន ៦១,៥% និងក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដែលមានភាគហ៊ុន ៣៨,៥%។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណផ្តល់សេវា និងធ្វើប្រតិបត្តិការទូរស័ព្ទចល័ត ឌីជីថល GSM នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៦។ ក្រុមហ៊ុនបានទទួលកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណថ្មី នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានសុពលភាព ៣០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាប័ណ្ណ និងអាចបន្តជាថ្មីសម្រាប់ចិរវេលាបន្ថែម ៥ឆ្នាំទៀត។ អាជ្ញាប័ណ្ណមួយសម្រាប់ប្រើប្រព័ន្ធ GSM និងការបែងចែកប្រេកង់ និងមួយទៀតប្រើសម្រាប់បច្ចេកវិទ្យា ៣G និងការបែងចែកប្រេកង់។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណផ្តល់សេវា និងធ្វើប្រតិបត្តិការសេវាពិធីការសម្លេងតាមអ៊ីនធឺណិត (VoIP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណសម្រាប់ការផ្តល់ និងប្រតិបត្តិការ ជាអ្នកផ្តល់សេវាអ៊ីនធឺណិត (ISP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្ព័ន្ធប្រើប្រាស់ពាក្យ "Cellcard" ជាឈ្មោះយីហោរបស់ខ្លួន សម្រាប់ការតភ្ជាប់ទូរស័ព្ទចល័ត និងអ៊ីនធឺណិត។ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណថ្មី ពីនិយ័តករទូរគមនាគមន៍កម្ពុជា សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទចល័តដោយប្រើបច្ចេកវិទ្យា ២G ៣G និង ៤G (LTE) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសុពលភាពរហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០៤៣។ អាជ្ញាប័ណ្ណថ្មីនេះ គឺជាការផ្ទេរពីអាជ្ញាប័ណ្ណដែលមានស្រាប់ចំនួនបី រួមមានអាជ្ញាប័ណ្ណចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទចល័តដោយប្រើបច្ចេកវិទ្យា ២G ៣G និង ៤G (LTE) ដែលផ្តល់ទៅឲ្យក្រុមហ៊ុន មូបីតែល ខមភេនី លីមីធីត និងអាជ្ញាប័ណ្ណចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទដោយការប្រើប្រាស់បច្ចេកវិទ្យា ៣G និងអាជ្ញាប័ណ្ណចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទចល័តដោយប្រើបច្ចេកវិទ្យា GSM ៩០០ & ១៨០០ ដែលបានផ្តល់ជូនក្រុមហ៊ុន។ ក្រោមអាជ្ញាប័ណ្ណថ្មីនេះ ក្រុមហ៊ុនមានសិទ្ធិ ផ្តល់សេវាទូរគមនាគមន៍ចល័តដោយប្រើប្រាស់បច្ចេកវិទ្យា ២G ៣G និង ៤G (LTE) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍ សេវាសម្លេង សេវាទិន្នន័យ សេវាអ៊ីនធឺណិត សេវាទូរស័ព្ទក្នុងស្រុក សេវាទូរស័ព្ទចម្ងាយឆ្ងាយ និងសេវាទូរស័ព្ទអន្តរជាតិ។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណផ្តល់សេវាអ៊ីនធឺណិត (ISP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណសម្រាប់ការផ្តល់ និងប្រតិបត្តិការ VoIP ក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបុត្រសម្ព័ន្ធមានដូចខាងក្រោម៖

- ក្រុមហ៊ុន មូបីតែល ខមភេនី លីមីធីត ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក និងត្រូវបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ ដោយផ្អែកទៅតាមលិខិតយោងអាជ្ញាប័ណ្ណលេខ CO ២៨២៤E/១៩៩៧។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ក្រុមហ៊ុន មូបីតែល ខមភេនី លីមីធីត បានទទួលអាជ្ញាប័ណ្ណពីនិយ័តករទូរគមនាគមន៍កម្ពុជា 'ន.ទ.ក.' ដើម្បីធ្វើប្រតិបត្តិការបច្ចេកវិទ្យា '4G' ដែលជាបច្ចេកវិទ្យាសម្រាប់ការវិវត្តរយៈពេលវែង។ បច្ចុប្បន្នក្រុមហ៊ុន Mobitel មិនមានប្រតិបត្តិការទេ។

- ក្រុមហ៊ុន Everyday Company Limited ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក និងត្រូវបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ យោងទៅតាមអាជ្ញាប័ណ្ណ CO ៥៥៦១/០១P។ បច្ចុប្បន្ន ក្រុមហ៊ុន Everyday មិនមានប្រតិបត្តិការទេ។

- នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ក្រុមហ៊ុន ថេឡេម៉ូបាយ (ខេមបូឌា) ឧបភើរេសិន (ជីស៊ីស៊ី) ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ ក្រុមហ៊ុន ខេម ជីអេសអេម ម.ក។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ធីស៊ីស៊ី ទទួលបានអាជ្ញាប័ណ្ណពីនិយ័តករទូរគមនាគមន៍ដើម្បីប្រតិបត្តិការសេវាបង្គោលអង់តែន ក្នុងព្រះរាជាណាចក្រកម្ពុជា។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាស

### ព្រឹត្តិការណ៍សំខាន់ៗក្នុងខែមេសា ឆ្នាំ២០២៥

### កញ្ចប់គម្រោង

❖ **គម្រោង សេរី+ សិស្ស!**

- គម្រោងថ្មីដែលសិស្សអាចរីករាយជាមួយគម្រោងប្រចាំខែដែលមានតម្លៃសមរម្យ ជាមួយនឹងទិន្នន័យសម្រាប់ការសិក្សា ការភ្ជាប់អ៊ីនធឺណិត និងបន្ថែម + 1GB ជារៀងរាល់ថ្ងៃសម្រាប់ការរៀនតាមរយៈគេហទំព័រស្ថាប័នផ្សព្វផ្សាយអប់រំកម្ពុជា (EBC)។

❖ **កញ្ចប់អ៊ីនធឺណិតរៀនបន្ថែម**

- ដំណើរការកម្មវិធីសិក្សាបន្ថែម ដែលល្អឥតខ្ចោះសម្រាប់សិស្សដែលមានភ្ជាប់គម្រោងរួចហើយ ប៉ុន្តែចង់ចូលប្រើទិន្នន័យបន្ថែមលើគេហទំព័រ EBC ដើម្បីសិក្សា។

❖ **ស៊ីមអេឡិចត្រូនិចនៅលើ Cellcard App & កញ្ចប់គម្រោង**

- ការដាក់ឱ្យប្រើប្រាស់ស៊ីមអេឡិចត្រូនិចនៅលើ Cellcard App ជាមួយនឹងផ្តល់ជូននូវ ស៊ីមអេឡិចត្រូនិចដោយឥតគិតថ្លៃ នៅពេលភ្ជាប់គម្រោង សេរី+ ១ដុល្លារ,៥ដុល្លារ, ៦ដុល្លារ , ១០ដុល្លារ។




កញ្ចប់ដាតាជំនួយ




eSIM នៅលើ Cellcard App




សេរី+ សិស្ស!




កញ្ចប់អ៊ីនធឺណិតរៀនបន្ថែម




អបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរក្នុងវីដេអូបទចម្រៀងរបស់ពេជ្ជរិទ្ធ

## ព្រឹត្តិការណ៍សំខាន់ៗក្នុងខែឧសភា ឆ្នាំ២០២៥

### កញ្ចប់គម្រោង

❖ **គម្រោងអ៊ីនធឺណិតរ៉ូមីងថៃ ឡាវ វៀតណាម**

- ដំណើរការគម្រោងអ៊ីនធឺណិតរ៉ូមីងថ្មីដែលអាចប្រើប្រាស់បានក្នុងប្រទេសថៃ វៀតណាម និងឡាវ។

### ការកែប្រែកញ្ចប់គម្រោង

❖ **គម្រោងអ៊ីនធឺណិតរ៉ូមីងនៅអាស៊ាន**

- អភិវឌ្ឍន៍គម្រោងរ៉ូមីងអាស៊ានពី 1GB តម្លៃ ៦ដុល្លារ ទៅ 3GB តម្លៃ ៦ដុល្លារ។

### កញ្ចប់គម្រោង និងព្រឹត្តិការណ៍ផ្សេងៗ

❖ **ស៊ីមយុគ៩ និងកញ្ចប់យុគ៩ & អនុស្សរណៈនៃការយោគយល់គ្នា**

- ការដំណើរការស៊ីមកាត ហុងស៊ុយ និងកញ្ចប់ហុងស៊ុយ។ ស័ក្តិសមបំផុតក្នុងការមើលហុងស៊ុយតាមទូរសព្ទដៃ និងទទួលបានលេខសំណាងដែលណែនាំដោយអ្នកគ្រូណាលី។




គម្រោងអ៊ីនធឺណិតរ៉ូមីងថៃ ឡាវ វៀតណាម




គម្រោងអ៊ីនធឺណិតរ៉ូមីងនៅអាស៊ាន




កញ្ចប់យុគ៩




ស៊ីមយុគ៩



អនុស្សរណៈនៃការយោគយល់គ្នា




ការបរិច្ចាគសប្បុរសធម៌




ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកប្រើប្រាស់តាមរយៈ EKYC




ការឆ្ពោះទៅរកអនាគតនៃសន្តិសុខសាយប័រនៅកម្ពុជាសម្រាប់ឆ្នាំ ២០២៥




កិច្ចប្រជុំដែលមានការចូលរួមជាមួយរដ្ឋមន្ត្រី ប.ទ.ក និងនាយកប្រតិបត្តិ NACSA




ការប្រកួតចុងក្រោយរបស់ MPL MLBB

## ព្រឹត្តិការណ៍សំខាន់ៗក្នុងខែមិថុនា ឆ្នាំ២០២៥

### ប្រូម៉ូសិន

❖ **កញ្ចប់ MLBB ពិសេស**

- ការដាក់ដំណើរការផ្តល់ជូនកញ្ចប់សម្រាប់អ្នកលេង MLBB។ ក្រុមហ៊ុនផ្តល់នូវកាដូរហូតដល់ ២.០០០ ហិប និងពេជ្រចំនួន ៣៥.០០០ ដល់អតិថិជនទាំងចាស់និងថ្មី

❖ **ប្រូម៉ូសិនលេខពិសេស**

- ប្រូម៉ូសិនលេខពិសេស (១៥% - ២៥%) នៅពេលទិញស៊ីមអេឡិចត្រូនិចនៅលើ CELLCARD APP

### កញ្ចប់គម្រោង

❖ **Traveler SIM**

- ការដំណើរការកញ្ចប់សេវាថ្មីសម្រាប់ទេសចរជាមួយនឹងការផ្តល់ជូនពិសេស - បញ្ចុះតម្លៃ ៥០% រាល់ការប្រើប្រាស់ Grab និងអាចទទួលបានការចុះតម្លៃនេះរហូតដល់ ៣ដងដែលក្នុងមួយដងមានការបញ្ចុះតម្លៃកំណត់យ៉ាងច្រើនត្រឹម ២ដុល្លារប៉ុណ្ណោះ។

❖ **Super Data SIM**

- ការដំណើរការកញ្ចប់សេវាថ្មីដែលមានសុពលភាពរយៈពេលវែងរហូតដល់ ៣៦៥ថ្ងៃ។ ល្អឥតខ្ចោះសម្រាប់ការដាក់ GPS តាមដានយានយន្ត ស្ថានីយម៉ាស៊ីនឆូតកាត (POS Terminals) ទូរអេជីអឹមកាមេរ៉ាសុវត្ថិភាព និង IoTs ។




កញ្ចប់ MLBB ពិសេស




ប្រូម៉ូសិនលេខពិសេស




Super Data SIM




Traveller SIM




ព្យុហយាត្រាសាមគ្គីភាព




ឯករាជ្យភាពឌីជីថល




ការបន្ថែមម៉ោងផ្តល់សេវាជូនអតិថិជន




ការផ្តល់មូនិធិជូនកងទ័ពការពារព្រំដែន




ពិព័រណ៍អាជីពជាតិ

## ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនបន្តមានសន្ទុះអភិវឌ្ឍន៍យ៉ាងខ្លាំងទៅលើផែនការពង្រីកហេដ្ឋារចនាសម្ព័ន្ធជាតិ និងបច្ចេកវិទ្យា។ ស្របតាមចក្ខុវិស័យរបស់ក្រុមហ៊ុន ក្នុងការផ្តល់នូវស្ថេរភាព និងការតភ្ជាប់នាពេលខាងមុខ ក្រុមហ៊ុនបានដាក់ចេញនូវគំនិតផ្តួចផ្តើមដែលមានប្រសិទ្ធភាពខ្ពស់ក្នុងគោលបំណងពង្រីកការគ្របដណ្តប់ការកែលម្អគុណភាពបណ្តាញ និងការពង្រឹងទំនុកចិត្តនៃសេវាកម្ម។

#### ១. ដំណើរការពង្រីកបណ្តាញគ្របដណ្តប់ទូទាំងប្រទេស

ដើម្បីបំពេញនូវតម្រូវការដែលកំពុងកើនឡើងក្នុងការប្រើប្រាស់សេវាទិន្នន័យនិងសារសម្លេងនៅទូទាំងប្រទេសកម្ពុជា ក្រុមហ៊ុនបន្តពង្រីកបណ្តាញគ្របដណ្តប់ ដែលបានចាប់ផ្តើមនៅដើមឆ្នាំ ២០២៥ នេះ។

- **ការពង្រីកបណ្តាញគ្របដណ្តប់ទូទាំងប្រទេស**
  នៅដំណាច់ត្រីមាសទី២ ចំនួនស្ថានីយអង់តែនទូរស័ព្ទចល័តថ្មីដែលបានគ្រោងទុកត្រូវបានបញ្ចប់ និងដាក់ឱ្យដំណើរការ ដោយបានពង្រឹងបណ្តាញគ្របដណ្តប់នៅទីតាំងសំខាន់ៗទូទាំងទីក្រុង និងតំបន់ជនបទដែលខ្វះខាតដូចជា ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តកំពង់ស្ពឺ ខេត្តតាកែវ រាជធានីភ្នំពេញ ខេត្តកោះកុង ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តកំពត ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ។
- **ការបង្កើនសមត្ថភាពស្ថានីយអង់តែនទូរស័ព្ទចល័ត**
  ដើម្បីសម្រួលដល់ការកកស្ទះ និងបង្កើនដំណើរការប្រតិបត្តិការឱ្យកាន់តែប្រសើរឡើង ក្រុមហ៊ុនបានពង្រឹងសមត្ថភាពស្ថានីយអង់តែនទូរស័ព្ទចល័តដែលមានស្រាប់ចំនួន ៦០០ស្ថានីយ នៅចុងត្រីមាសទី២។ ការពង្រឹងសមត្ថភាពស្ថានីយអង់តែនទូរស័ព្ទចល័តទាំងនេះបានលាតសន្ធឹងលើខេត្តសំខាន់ៗរួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងឧត្តរមានជ័យ។
- **ការដាក់ពង្រាយបណ្តាញខ្សែកាប្លីហេដ្ឋារចនាសម្ព័ន្ធ**
  ក្រុមហ៊ុនបានដាក់ពង្រាយបណ្តាញខ្សែកាប្លីដែលមានចម្ងាយប្រមាណ១០០០គីឡូម៉ែត្រនៃបណ្តាញហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លីអុបទិកថ្មីទូទាំងប្រទេស។ ការដាក់ឱ្យដំណើរការនេះគឺជាការពង្រឹងការតភ្ជាប់បណ្តាញទូរស័ព្ទចល័ត ការតភ្ជាប់កម្រិតសហគ្រាស និងរៀបចំបណ្តាញសម្រាប់សេវាកម្មដែលមានសមត្ថភាពខ្ពស់ និងត្រៀមរួចជាស្រេចសម្រាប់តម្រូវការនាពេលអនាគត។
- **ការពង្រឹងការតភ្ជាប់បណ្តាញបញ្ជូនមេ– ភាគខាងជើងប្រទេសកម្ពុជា**
  ការតភ្ជាប់បណ្តាញបញ្ជូនមេនៅតំបន់ភាគខាងជើងប្រទេសកម្ពុជាកំពុងតែបន្តពង្រឹងសមត្ថភាពដើម្បីពង្រីកការតភ្ជាប់។ គំនិតផ្តួចផ្តើមនេះនឹងធ្វើឱ្យមានស្ថេរភាពទិន្នន័យ បង្កើនការប្រតិបត្តិការ និងគាំទ្រដល់សមត្ថភាពផ្សារភ្ជាប់ជាមួយនឹងកំណើនប្រើប្រាស់ក្នុងតំបន់ក្នុងរយៈពេលវែង។

#### ២. EMS+ ជាមួយ IPDR៖ ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនិងអនុលោមតាមគោលការណ៍របស់និយ័តករទូរគមន៍កម្ពុជា

ក្រុមហ៊ុនបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យ EMS+ (Enhanced Management System Plus) ដោយបញ្ចូលការកត់ត្រាព័ត៌មានលម្អិតអំពីការប្រើប្រាស់អ៊ីនធឺណិត (IPDR) ដើម្បី

អនុលោមតាមតម្រូវការនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) និងប្រើប្រាស់ក្នុងការប្រតិបត្តិការពាណិជ្ជកម្មរបស់ក្រុមហ៊ុន។

**៣.ការពង្រឹងបណ្តាញ និងនិរន្តរភាព តាមរយៈការផ្គត់ផ្គង់ថាមពល**

ក្រុមហ៊ុនកំពុងបន្តកិច្ចខិតខំប្រឹងប្រែងពង្រឹងបណ្តាញសេវារបស់ខ្លួនតាមរយៈការពង្រីកនូវប្រព័ន្ធផ្គត់ផ្គង់ថាមពល។ ការជំនួសប្រព័ន្ធថ្មអាស៊ីត (lead-acid battery) ជាមួយនឹង lithium battery កម្រិតខ្ពស់ឱ្យលឿនតាមដែលអាចធ្វើទៅបាន។ ការតម្លើងនេះ នឹងធ្វើអោយមានប្រសិទ្ធភាពថាមពលកាន់តែប្រសើរឡើង ពង្រីកសមត្ថភាពដំណើរការបម្រុងទុក និងបង្កើនសមត្ថភាពក្នុងអំឡុងពេលមានការរំខាន។ ថាមពលថ្មីនេះមិនត្រឹមតែមិនប៉ះពាល់ដល់បរិស្ថាននោះទេ ហើយ ថែមទាំងរួមចំណែកដល់ការខិតខំប្រឹងប្រែងប្រកបលើនិរន្តរភាពរបស់ក្រុមហ៊ុនផងដែរ។

បន្ថែមពីលើការពង្រឹងថាមពល ក្រុមហ៊ុនក៏កំពុងកែលម្អមជ្ឈមណ្ឌលទិន្នន័យសំខាន់ៗ តាមរយៈការដាក់បំពាក់ឧបករណ៍ផុងត្រជាក់សម្រាប់ម៉ាស៊ីនមេ។ ឧបករណ៍ផុងត្រជាក់ទាំងនេះនឹងកាត់បន្ថយការប្រើប្រាស់ថាមពល នឹងពង្រីកសមត្ថភាពដល់វដ្តដំណើរការប្រើប្រាស់ឧបករណ៍តាមរយៈការគ្រប់គ្រងបរិស្ថាន។

ក្រុមហ៊ុន នៅតែផ្តោតយ៉ាងមុតមាំលើការអនុវត្តផែនការពង្រីកបណ្តាញឆ្នាំ២០២៥ ប្រកបដោយវិន័យ និងភាពច្បាស់លាស់។ ជាមួយនឹងការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទូរស័ព្ទ ខ្សែកាប្លិ៍ និងស្នូល ក្រុមហ៊ុនមានទីតាំងល្អក្នុងការផ្តល់នូវតម្លៃរយៈពេលវែងសម្រាប់អតិថិជន និងដើម្បីកសាងបណ្តាញទូរស័ព្ទចល័តដែលផ្តល់ទំនុកចិត្តខ្ពស់ និងបណ្តាញសេវារឹងមាំក្នុងប្រទេសកម្ពុជា។

## ខ. រចនាសម្ព័ន្ធនៃចំណូលក្រុមហ៊ុន

សូមពិនិត្យព័ត៌មានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃចំណូលក្រុមហ៊ុន ដូចមានក្នុងតារាងខាងក្រោម។ សម្រាប់ព័ត៌មានលម្អិត និងការបញ្ជាក់បន្ថែម សូមពិនិត្យផ្នែកទី៤ នៃរបាយការណ៍នេះ។

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២- ឆ្នាំ២០២៥ | | ត្រីមាសទី២- ឆ្នាំ២០២៤ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| ១ | ការផ្តល់សេវាទូរគមនាគមន៍ | ១៦៥.២១១ | ៩៥% | ១៧៣.៨២២ | ៩៧% |
| ២ | ចំណូលពីការភ្ជាប់សេវា និង ចំណូលពីការជាវសេវា | ៥.៨៨៨ | ៣% | ៣.៤៨១ | ២% |
| ៣ | ចំណូលភតិសន្យា | ៤៧២ | ១% | - | 0% |
| ៤ | ចំណូលផ្សេងៗ | ១.៧១២ | ១% | ១.៣៣២ | ១% |
| **ចំណូលសរុប** | | **១៧៣.២៨៣** | **១០០%** | **១៧៨.៦៣៥** | **១០០%** |

## <u>ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ</u>

សូមពិនិត្យមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល ៣ខែ បញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

## ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ ផ្តោតលើលទ្ធផលនៃប្រតិបត្តិការ និងហិរញ្ញវត្ថុ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមចន្លោះពេល គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ដែលបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមចន្លោះពេល ត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"។ មានតែសមាសធាតុសំខាន់ៗ នៃរបាយការណ៍ហិរញ្ញវត្ថុរួមចន្លោះពេល និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ខេម ជ្ជីអេសអេម តែប៉ុណ្ណោះទេ ដែលនឹងយកមកពិភាក្សា។

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលចម្បងរបស់ក្រុមហ៊ុន ខេម ជ្ជីអេសអេម គឺបានមកពីការផ្តល់សេវាទូរគមនាគមន៍ ការតភ្ជាប់និងទិញសេវា បរិក្ខារ ចំណូលភតិសន្យា និងចំណូលផ្សេងៗ។

i. **<u>ចំណូលពីការផ្តល់សេវាទូរគមនាគមន៍</u>៖** រួមមានកម្រៃ ដែលបានពីការប្រើប្រាស់សេវាទូរស័ព្ទ កម្រៃភ្ជាប់សេវាទំនាក់ទំនង កម្រៃភ្ជាប់សេវារ៉ូមមីង និងសេវាទូរគមនាគមន៍ផ្សេងៗដូចជា សេវាទិន្នន័យ សេវាបញ្ជូនសារខ្លីៗ និងសេវាតម្លៃបន្ថែមផ្សេងៗ។

ii. **<u>ចំណូលពីការភ្ជាប់ និងការទិញសេវា</u>៖** រួមមានកម្រៃដែលបានពីការទិញសេវា និងការលក់ស៊ីមកាត និងឋិរវេលាប្រើប្រាស់ដែលបានផ្ទុកជាមុន។

iii. **<u>ចំណូលភតិសន្យា</u>៖** បានពីការជួលទីតាំងសម្រាប់បំពាក់សម្ភារៈនៅលើអង់តែនទូរគមនាគមន៍ ដែលអតិថិជននីមួយៗដំឡើងនឹងរក្សាទុកឧបករណ៍បណ្តាញទំនាក់ទំនង។

iv. **<u>ចំណូលផ្សេងៗ</u>៖** គឺចំណូលពីការលក់លេខស៊ីមកាតពិសេស និងសេវាកម្មផ្សេងទៀតដែលរួមបញ្ចូលទាំងចំណូលផ្សេងទៀតដែលមិនកើតឡើងដដែលៗផ្សេងទៀត (non-recurring revenue)។

#### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២- ឆ្នាំ២០២៥ | | ត្រីមាសទី២- ឆ្នាំ២០២៤ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| ១ | ចំណូលពីការផ្តល់សេវាទូរគមនាគមន៍ | ១៦៥.២១១ | ៩៥% | ១៧៣.៨២២ | ៩៧% |
| ២ | ចំណូលពីការភ្ជាប់ និងការទិញសេវា | ៥.៨៨៨ | ៣% | ៣.៤៨១ | ២% |
| ៣ | ចំណូលភតិសន្យា | ៤៧២ | ១% | - | 0% |
| ៤ | ចំណូលផ្សេងៗ | ១.៧១២ | ១% | ១.៣៣២ | ១% |
| **ចំណូលសរុប** | | **១៧៣.២៨៣** | **១០០%** | **១៧៨.៦៣៥** | **១០០%** |

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៥ ចំណូលសរុបបានថយចុះចំនួន ៥.៣៥២ លានរៀល ឬ ៣% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤ ដែលបណ្តាលមកពីការថយចុះនៃចំណូលពីការផ្តល់សេវាទូរគមនាគមន៍ចំនួន ៨.៦១១ លានរៀល ឬ ៥%។

## ៣. ការវិភាគគម្លាតចំណេញដុល

គម្លាតចំណេញដុល បន្តរក្សាស្ថិរភាពជាមួយអត្រា៧២% នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៥។

## ៤. ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៤ | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ចំនួនទឹកប្រាក់ | % |
| **ចំណូល** | **១៧៣.២៨៣** | **១៧៨.៦៣៥** | **(៥.៣៥២)** | **(៣%)** |
| **ចំណាយប្រតិបត្តិការ** | | | | |
| ចំណាយរំលស់លើទ្រព្យសកម្មរូបី និងអរូបី | (៣៣.៣៤២) | (៣៦.៤៣៦) | ៣.០៩៤ | ៨% |
| ចំណាយភ្ជាប់បណ្តាញទូរស័ព្ទឆ្លងប្រព័ន្ធ | (១.៩៥០) | (៣.២៤២) | ១.២៩២ | ៤០% |
| ចំណាយបុគ្គលិក | (១៣.៩២៧) | (១៥.០៦៩) | ១.១៤២ | ៨% |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៨១.៩៦៣) | (៧៦.៥០៤) | (៥.៤៥៩) | (៧%) |
| ចំណេញ(ខាត)ផ្សេងៗ - សុទ្ធ | (២១) | (១០៣) | ៨២ | ៨០% |
| **ចំណេញប្រតិបត្តិការ** | **៤២.០៨០** | **៤៧.២៨១** | **(៥.២០១)** | **(១១%)** |
| ចំណូលហិរញ្ញវត្ថុ | ១៣៨ | ១.៥០៦ | (១.៣៦៨) | (៩១%) |
| ចំណាយហិរញ្ញវត្ថុ | (២៤.១៧៨) | (២៥.២៩២) | ១.១១៤ | ៤% |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | **១៨.០៤០** | **២៣.៤៩៥** | **(៥.៤៥៥)** | **(២៣%)** |

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៥ ចំណេញប្រតិបត្តិការបានថយចុះចំនួន ៥.២០១ លានរៀល ឬ ១១% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤ បណ្តាលមកពី ការថយចុះនៃចំណូលពីការផ្តល់សេវាទូរគមនាគមន៍។ ចំណេញមុនពន្ធលើប្រាក់ចំណូលបានថយចុះ ចំនួន ៥.៤៥៥ លានរៀល ឬ ២៣% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤ ដោយសារការថយចុះចំណេញប្រតិបត្តិការ។

## ៥. ការវិភាគចំណេញ/(ខាត) ក្រោយបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៤ | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ចំនួនទឹកប្រាក់ | % |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | ១៨.០៤០ | ២៣.៤៩៥ | (៥.៤៥៥) | (២៣%) |
| (ចំណាយ)/ឥណទានពន្ធលើប្រាក់ចំណូល | (៣.១០៧) | (៥.១៦៤) | ២.០៥៧ | ៤០% |
| **ចំណេញក្នុងការិយបរិច្ឆេទ** | ១៤.៩៣៣ | ១៨.៣៣១ | (៣.៣៩៨) | (១៩%) |

ក្រុមហ៊ុន ខេម ជីអេសអេម មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា នៃផលរបរស្របតាមច្បាប់ស្តីពីពន្ធដារ។ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤ ក្រុមហ៊ុន ខេម ជីអេសអេម បានទទួលលិខិតលេខ ៩៧២៦ ពីអគ្គនាយកដ្ឋានពន្ធដារ ដែលអនុញ្ញាតចំពោះការអនុគ្រោះពន្ធលើប្រាក់ចំណូលចំនួន ៣ឆ្នាំ សម្រាប់ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។ ការអនុគ្រោះនេះ យកវិធីគណនានៃការអនុគ្រោះពន្ធលើប្រាក់ចំណូល ដែលមានប្រភាគថយចុះស្របតាមតារាង ដែលមានក្នុងឧបសម្ព័ន្ធនៃអនុក្រឹត លេខ៤២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។ អគ្គនាយកដ្ឋានពន្ធដារ ក៏បានអនុញ្ញាតការផ្អាកជាបណ្តោះអាសន្ន ចំពោះការបង់ពន្ធប្រាក់ចំណូលប្រចាំខែជាមុន សម្រាប់រយៈពេលនៃការអនុគ្រោះពន្ធលើប្រាក់ចំណូល។

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ ក្រុមហ៊ុន ខេមជីអេសអេម បានរាយការណ៍ពីចំណេញក្នុងការិយបរិច្ឆេទមានចំនួន ១៤.៩៣៣ លានរៀល ដែលបានថយចុះចំនួន ៣.៣៩៨ លានរៀល ស្មើនឹង ១៩% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៤។ ការថយចុះនៃចំណេញក្នុងការិយបរិច្ឆេទ បណ្តាលមកពីការថយចុះចំណេញប្រតិបត្តិការ។

## ៦. ការវិភាគចំណូលលម្អិតសរុប(ខាត)

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៥ | ត្រីមាសទី២ ឆ្នាំ២០២៤ | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ចំនួនទឹកប្រាក់ | % |
| **ចំណេញក្នុងការិយបរិច្ឆេទ** | ១៤.៩៣៣ | ១៨.៣៣១ | (៣.៣៩៨) | (១៩%) |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| *ខ្ទង់ដែលមិនត្រូវបាត់ថ្នាក់ឡើងវិញ* | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ១៩ | ១៣៥ | (១១៦) | (៨៦%) |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | ១៤.៩៥២ | ១៨.៤៦៦ | (៣.៥១៤) | (១៩%) |

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៥ ក្រុមហ៊ុន ខេម ជីអេសអេម បានប្រកាសលទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ ចំនួន ១៤.៩៥២ លានរៀល ដែលបានថយចុះចំនួន ៣.៥១៤ លានរៀល ស្មើនឹង ១៩% បើធៀបនឹងត្រីមាស ទី២ ឆ្នាំ២០២៤។ ការថយចុះនៃចំណេញក្នុងការិយបរិច្ឆេទ បណ្តាលមកពីការថយចុះចំណេញប្រតិបត្តិការ។

### ៧. ការវិភាគលើកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០២៥ វិស័យទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជាបានជួបប្រទះការផ្លាស់ប្តូរផ្នែក ប្រតិបត្តិការ និងយុទ្ធសាស្រ្តដែលបណ្តាលមកពីកត្តាវិវឌ្ឍន៍នៃភូមិសាស្រ្តនយោបាយ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធ។ គួរបញ្ជាក់ផងដែរថា ជម្លោះព្រំដែនរវាងប្រទេសកម្ពុជានិងប្រទេសថៃបានឈានដល់ការបិទច្រកព្រំដែននៅចុងខែមិថុនា និងបានផ្តល់ផលប៉ះពាល់ដល់ការតភ្ជាប់បណ្តាញខ្សែកាប្លិ៍ឆ្លងកាត់ព្រំដែនសំខាន់ៗ រួមមានការនាំចូលអគ្គិសនី ដែលពីមុនការតភ្ជាប់នេះជួយគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់កម្ពុជា។

ទោះបីជាមានបញ្ហាប្រឈមនេះក្តី ក្រុមហ៊ុនបានឆ្លើយតបនឹងបញ្ហានេះយ៉ាងមុតមាំក្នុងការបង្កើនសមត្ថភាព សេវាជៀសវៀងការបង្អាក់ និងបន្តផ្តល់ជូននូវសេវាកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់។ កត្តាទាំងនេះបានជំរុញ ក្រុមហ៊ុនស្វែងរកដំណោះស្រាយជុំវិញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការពឹងផ្អែកលើកម្លាំងថាមពលក្នុង ស្រុក និងយុទ្ធសាស្រ្តធ្វើពិពិធកម្ម ដែលនាំឱ្យក្រុមហ៊ុននៅតែមានគោលជំហររឹងមាំ និងបង្កើនយុទ្ធសាស្រ្ត គ្រប់គ្រង។ ទោះបីជាត្រីមាសទី២នេះបានជួបនូវឧបសគ្គរាំងដល់វឌ្ឍនភាពភូមិសាស្រ្តនយោបាយ និងការ ដឹកជញ្ជូនក្តី ក៏កត្តាទាំងនេះបានឆ្លុះបញ្ចាំងពីសក្តានុភាពក្នុងការជំរុញស្ថិរភាពជាតិ ក៏ដូចជាការបើកទំព័រថ្មីក្នុង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលឯករាជ្យក្នុងរយៈពេលវែងផងដែរ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើប្រាក់ចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ក្រុមហ៊ុន បានបន្តមានតម្រូវការទាំងសេវាទូរស័ព្ទចល័ត និងទិន្នន័យ ដោយសារការបន្តប្រើប្រាស់ប្រព័ន្ធឌីជីថល និងដោយសារការកើនឡើងនៃការប្រើប្រាស់កម្មវិធីឌីជីថលផ្សេងៗ។ ខណៈដែលកំណើនអតិថិជនថ្មីបានថយ ចុះនៅក្នុងទីផ្សារ ការប្រើប្រាស់ទិន្នន័យជាមធ្យមរបស់អ្នកប្រើប្រាស់បន្តកើនឡើង ដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ ឆ្ពោះទៅរកកំណើននៃការប្រើប្រាស់។

ចំពោះផ្នែកផ្គត់ផ្គង់ ការបិទព្រំដែន និងការផ្តាច់បណ្តាញអ៊ីនធឺណិតទាំងអស់ជាមួយប្រទេសថៃ បានផ្តល់ផល រំខានដល់ការនាំចូលឧបករណ៍ទូរគមនាគមន៍ និងបណ្តាញសេវាអ៊ីនធឺណិតនៅក្នុងតំបន់មួយចំនួន។ កត្តានេះ នាំឱ្យមានការពន្យាពេលការពង្រីកបណ្តាញ និងការកើនឡើងការចំណាយលើប្រតិបត្តិការ។ ទោះបីជាមានបញ្ហា ទាំងនេះក៏ដោយ កម្រិតសេវាកម្មនៅតែមានស្ថេរភាព ដោយផ្អែកលើវិធានការទប់ស្កាត់របស់ក្រុមហ៊ុន។

### ២. ការវិភាគពីការឡើងចុះនៃតម្លៃវត្ថុធាតុដើម

ក្រុមហ៊ុនមិនមានវត្ថុធាតុដើមសម្រាប់ផលិត ផលិតផលឬសេវាកម្មនោះទេ។

### ៣. ការវិភាគលើពន្ធ

ក្រុមហ៊ុន មានកាតព្វកិច្ចក្នុងការបង់ពន្ធជូនរាជរដ្ឋាភិបាល ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន ជាប់ជាក្រុមហ៊ុនជាប់ពន្ធធំ និងតម្រូវឲ្យបង់ពន្ធស្របតាមប្រព័ន្ធដូចបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំណាយពន្ធរួមមាន ពន្ធដែលបានបង់ក្នុងអំឡុងឆ្នាំសារពើពន្ធ និងពន្ធពន្យារពេល។ ការចំណាយលើពន្ធប្រាក់ ចំណូលត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ/ខាត។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ក្នុងផ្នែកនេះ មិនមានធាតុពិសេសណាមួយ ដែលប៉ះពាល់ដល់ដំណើរការហិរញ្ញវត្ថុ ក្នុងកំឡុងត្រីមាសនេះឡើយ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ នេះ ប្រាក់ចំណូលសរុបបានធ្លាក់ចុះ ៣,៨% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៤ ប៉ុន្តែបានកើនឡើងចំនួន ៤% ពីត្រីមាសទី១ ឆ្នាំ២០២៥ ។ សេវាដែលបានជំរុញឱ្យមានការស្ទុះងើបឡើងវិញនេះគឺៈ ប្រាក់ចំណូលពីកញ្ចប់គម្រោង (+៤% ពីត្រីមាសមួយទៅត្រីមាសមួយ) ហើយប្រាក់ចំណេញបន្ថែមកើនឡើងចំនួន ១៤% ពីគម្រោងបន្ថែមអ៊ីនធឺណិត។

ផ្នែកសេវាកម្មផ្សេងទៀតបានបង្ហាញពីលទ្ធផលផ្សេងៗគ្នា។ សេវារ៉ូមីងក្នុងប្រទេសបានកើនឡើង ៥៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន និង +១៣% ពីត្រីមាសមួយទៅត្រីមាសមួយឆ្នាំ២០២៥។ ចំណែកឯ សេវារ៉ូមីងក្រៅប្រទេសបានកើនឡើង ១% និងសេវាកម្មមិនមែនទូរគមនាគមន៍ផ្សេងទៀតបានកើនឡើង ១៦% ពីត្រីមាសទី១ ឆ្នាំ២០២៥ ។អ្នកប្រើប្រាស់បង់ប្រាក់ប្រចាំខែ និងសាជីវកម្មទាំងពីរបានកើនឡើង ៤% ពីត្រីមាសមួយទៅត្រីមាសមួយ។ និន្នាការទាំងនេះបង្ហាញពីការផ្លាស់ប្តូរនៃការតភ្ជាប់សេវា ក្នុងខណៈពេលដែលពង្រីកការភ្ជាប់សេវាកម្ម ។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ចំណូលពីការលក់ និងការទិញរបស់ក្រុមហ៊ុន ខេម ជីអេសអេម គឺភាគច្រើនត្រូវបានប្រើប្រាស់ជាលុយដុល្លារអាមេរិក (USD)។ ហេតុដូចនេះក្រុមហ៊ុន ខេម ជីអេសអេម មិនមានរងផលប៉ះពាល់ខ្លាំង ពីការប្រែប្រួលនៃអត្រាប្តូរប្រាក់បរទេសនោះទេ។

កម្ចីរបស់ក្រុមហ៊ុន ក៏ប្រកាន់យករបបអត្រាការប្រាក់អណ្តែត ដូច្នេះក្រុមហ៊ុន ខេម ជីអេសអេម នឹង បង់ការប្រាក់បន្ថែមជាមួយនឹងការកើនឡើងនៃអត្រាទីផ្សារ។

## ង. ផលប៉ះពាល់នៃអតិផរណា

អតិផរណា គឺជាអត្រានៃការកើនឡើងថ្លៃ នៅក្នុងអំឡុងពេលជាក់លាក់មួយ។ ជាទូទៅអតិផរណា គឺជាវិធានការទូលំទូលាយ ដូចជាការកើនឡើងនៃថ្លៃ ឬការកើនឡើងនៃថ្លៃរស់នៅប្រចាំថ្ងៃ។ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ អត្រាអតិផរណារបស់ប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងនៅតែមានកម្រិតមធ្យមក្នុងកម្រិត ២,៦% នៅឆ្នាំ២០២៥ ដែលឆ្លុះបញ្ចាំងពីការកើនឡើង 0,៨ % ធៀបនឹងឆ្នាំមុន។ ដោយសារការកំណត់តម្លៃ របស់ក្រុមហ៊ុន និងនៅក្នុងកិច្ចសន្យារយៈពេលវែងជាមួយអ្នកផ្គត់ផ្គង់នឹងមិនប៉ះពាល់ដោយការប្រែប្រួលតម្លៃក្នុងរយៈពេលខ្លីនោះទេ ដូចនេះការកើនឡើងនៃអត្រាអតិផរណានឹងប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុនខ្លាំងខ្លានោះទេ។

## ច. គោលការណ៍សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

គោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា បន្តសម្របខ្លួនតាមក្របខ័ណ្ឌគោលនយោបាយក្នុងការឆ្ពោះទៅមុខដើម្បីគាំទ្រការអភិវឌ្ឍន៍និរន្តរភាព ការវិនិយោគ និងការផ្លាស់ប្តូរប្រព័ន្ធឌីជីថល។ ប្រទេសកម្ពុជាមានគោលដៅប្រែក្លាយប្រទេសទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ (យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ខែសីហា ឆ្នាំ២០២៣) រាជរដ្ឋាភិបាលបានអនុវត្តកំណែទម្រង់សេដ្ឋកិច្ចទូលំទូលាយ ដើម្បីពង្រឹងការប្រកួត

ប្រជែង ភាពធន់ និងតម្លាភាព។ កត្តាទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងស្របតាមកិច្ចខិតខំប្រឹងប្រែងជាតិដើម្បីធ្វើទំនើបកម្មសេដ្ឋកិច្ច និងទាក់ទាញការវិនិយោគប្រកបដោយនិរន្តរភាព។

- **សេដ្ឋកិច្ចចម្រុះ៖** ដើម្បីគាំទ្រដល់ការផ្លាស់ប្តូររបស់ប្រទេសកម្ពុជាឆ្ពោះទៅកាន់សេដ្ឋកិច្ចចម្រុះ ដោយផ្អែកលើចំណេះដឹងសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានផ្តល់អាទិភាពដល់ការធ្វើបរិវត្តឌីជីថលជាអាទិ៍ដើម្បីសម្រេចគោលដៅ។ ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥ ចក្ខុវិស័យនេះសង្កត់ធ្ងន់លើការពង្រីក និងទំនើបកម្មនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងទូរគមនាគមន៍ ជាមូលដ្ឋានគ្រឹះសម្រាប់កំណើន និងការរួមបញ្ចូលជាតិ។ យុទ្ធសាស្ត្រគោលនយោបាយសំខាន់ៗដែលប្រហាក់ប្រហែលគ្នានឹងក្រុមហ៊ុនរួមមាន: i) ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធការតភ្ជាប់ឌីជីថល ii) ការបង្កើតវេទិកាផ្លាស់ប្តូរទិន្នន័យ (CamDX) និងការពង្រឹងប្រកទ្វារអ៊ីនធឺណិតជាតិ iii) កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល (យុទ្ធសាស្ត្រទី៩) និងការលើកកម្ពស់ការចាប់ផ្តើមអាជីវកម្មឌីជីថល (យុទ្ធសាស្ត្រទី១០) ។ ដើម្បីគាំទ្រចក្ខុវិស័យនេះ ក្រុមហ៊ុនបន្តពង្រីកបណ្តាញខ្សែកាប្លិ៍ ធ្វើទំនើបកម្មបណ្តាញអ៊ីនធឺណិត និងធ្វើឱ្យ ហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើង ដើម្បីធ្វើឱ្យមានការតភ្ជាប់ប្រកបដោយសុវត្ថិភាព និងសមត្ថភាពខ្ពស់។ ហេដ្ឋារចនាសម្ព័ន្ធនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រវេទិការដ្ឋាភិបាលឌីជីថល ជំរុញកំណើននៃការចាប់ផ្តើមអាជីវកម្មក្នុងស្រុក និងការកសាងបណ្តាញតភ្ជាប់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលត្រៀមរួចជាស្រេចសម្រាប់ពេលអនាគត។
- **ការជម្រុញការវិនិយោគ៖** ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) និង ជម្រុញការវិនិយោគក្នុងស្រុក រដ្ឋាភិបាលបានអនុវត្តគោលនយោបាយកែលម្អបរិយាកាសធុរកិច្ច សម្រួលដំណើរការបទប្បញ្ញត្តិ និងផ្តល់ការលើកទឹកចិត្តសម្រាប់អ្នកវិនិយោគ។ គំនិតផ្តួចផ្តើមគួរឱ្យកត់សម្គាល់មួយរួមមានការចេញមូលបត្របំណុលហេដ្ឋារចនាសម្ព័ន្ធ យន្តការហិរញ្ញវត្ថុដែលកំពុងលេចចេញដើម្បីប្រមូលមូលធនឯកជនទៅក្នុងវិស័យសំខាន់ៗដូចជាហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងទូរគមនាគមន៍។ សកម្មភាពនេះមិនត្រឹមតែធ្វើពិពិធកម្មប្រភពមូលនិធិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងទំនុកចិត្តរបស់អ្នកវិនិយោគលើយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជា។
- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋាភិបាលបានផ្តល់អាទិភាពដល់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងការសាងសង់ផ្លូវថ្នល់ ការពង្រីកកំពង់ផែ និងការវិនិយោគលើវិស័យថាមពល។ គំនិតផ្តួចផ្តើមទាំងនេះមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការតភ្ជាប់ សម្រួលពាណិជ្ជកម្ម និងលើកកម្ពស់ការប្រកួតប្រជែង របស់ប្រទេសនៅលើឆាកតំបន់ និងពិភពលោក។
- **គោលនយោបាយសារពើពន្ធ៖** វិធានការគោលនយោបាយសារពើពន្ធ ផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការកែលម្អការប្រមូលចំណូល និងការគ្រប់គ្រងការចំណាយសាធារណៈប្រកបដោយប្រសិទ្ធភាព។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីពង្រីកមូលដ្ឋានពន្ធ បង្កើនការអនុលោមតាមពន្ធ និងពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានានិរន្តរភាពសារពើពន្ធ។
- **គោលនយោបាយរូបិយវត្ថុ៖** ធនាគារជាតិនៃកម្ពុជា (NBC) បានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយការប្រុងប្រយ័ត្ន សំដៅរក្សាស្ថិរភាពតម្លៃ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

វិធានការរួមមាន ការគ្រប់គ្រងអត្រាការប្រាក់ ការគ្រប់គ្រងសម្ពាធអតិផរណា និងការត្រួតពិនិត្យវិស័យធនាគារដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ។

- **កម្មវិធីសុខុមាលភាពសង្គម៖** រាជរដ្ឋាភិបាលបានពង្រីកកម្មវិធីសុខុមាលភាពសង្គម ដើម្បីដោះស្រាយបញ្ហាកាត់បន្ថយភាពក្រីក្រ កែលម្អការថែទាំសុខភាព និងលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ។ ការវិនិយោគត្រូវបានធ្វើឡើងនៅក្នុងហេដ្ឋារចនាសម្ព័ន្ធសង្គម រួមទាំងកន្លែងថែទាំសុខភាព និងសាលារៀន ដើម្បីបង្កើនគុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។
- **ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល៖** គោលនយោបាយត្រូវបានណែនាំដើម្បីលើកកម្ពស់ការអភិវឌ្ឍ សេដ្ឋកិច្ចឌីជីថល រួមទាំងពាណិជ្ជកម្មអេឡិចត្រូនិក ការទូទាត់តាមឌីជីថល និងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន។ គំនិតផ្តួចផ្តើមមានគោលបំណងជំរុញការបង្កើតថ្មី ភាពជាសហគ្រិន និងការដាក់បញ្ចូលឌីជីថល ដើម្បីទាញយកសក្តានុពលនៃបច្ចេកវិទ្យាសម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។

ក្រុមហ៊ុន ខេម ជ្ជីអេសអេម រួមចំណែកក្នុងចក្ខុវិស័យ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ហើយប្រកាន់ខ្ជាប់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ៥រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥
បានអាន និងឯកភាព
ហត្ថលេខា



**អ្នកឧកញ៉ា គិត ម៉េង**
**ប្រធានក្រុមប្រឹក្សាភិបាល**

**ក្រុមហ៊ុន ខេម ជីអេសអេម ម.ក**

33 មហាវិថីព្រះសីហនុ ប្រអប់សំបុត្រ
2468 ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

+855 12 800 800
www.cellcard.com.kh

# ក្រុមហ៊ុន ខេម ឌីអេសអេម ម.ក

## ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល
## សម្រាប់រយៈពេល ៣ខែ និង ៦ខែ បញ្ចប់
## នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

**ក្រុមហ៊ុន ខេម ជីអេសអេម ម.ក**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល**
**សម្រាប់រយៈពេល ៣ខែ និង ៦ខែ បញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥**

| **មាតិកា** | **ទំព័រ** |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល | ២ – ៣ |
| របាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួមចន្លោះពេល | ៤ – ៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបរួមចន្លោះពេល | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបរួមចន្លោះពេល | ៧ – ៨ |
| កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល | ៩ – ២៤ |
| របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល | ២៥ – ២៦ |

33 មហាវិថី ព្រះសីហនុ
ប្រអប់សំបុត្រ 2468 ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

33 Preah Sihanouk Blvd,
P.O. Box 2468, Phnom Penh,
Kingdom of Cambodia
+855 12 800 800
www.cellcard.com.kh

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

តាងនាមឱ្យក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (ហៅកាត់ជារួមថា "សម្ព័ន្ធ") គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល៣ខែ និង៦ខែ ដែលបានបញ្ចប់ របាយការណ៍បម្រែបម្រួលមូលធនសង្ខេបរួមចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល៦ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល (ត្រូវបានគេស្គាល់ជារួមថា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល") ដែលបានភ្ជាប់មកជាមួយនេះ ត្រូវបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

ចុះហត្ថលេខាស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ខេម ជីអេសអេម ម.ក CAMGSM PLC. KINGDOM OF CAMBODIA

.................................................

**លោក Yap Kok Leong**
**នាយកប្រតិបត្តិ**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 12 AUG 2025

## ក្រុមហ៊ុន ខេម ជីអេសអេម ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល
## គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

| | | មិនបានធ្វើសវនកម្ម | | បានធ្វើសវនកម្ម | |
|---|---|---|---|---|---|
| | កំណត់ | ៣០ មិថុនា ២០២៥ | | ៣១ ធ្នូ ២០២៤ | |
| | សម្គាល់ | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | ១១៦.៥១៩.៧៣៦ | ៤៦៧.២៤៤ | ១០៤.៨០៤.៨៥៨ | ៤២១.៨៤០ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | | ១២២.៨៣១.៩៤៦ | ៤៩២.៥៥៦ | ១១៩.៦០៣.៨៥២ | ៤៨១.៤០៦ |
| ទ្រព្យសកម្មអរូបី | | ១.៣២៥.៥៨១ | ៥.៣១៦ | ១.៥២០.៨៤២ | ៦.១២១ |
| បុរេប្រទានឱ្យអ្នកផ្គត់ផ្គង់សម្រាប់ការទិញ ទ្រព្យសកម្ម | | ២.៣២១.៧១៣ | ៩.៣១០ | ២.១២៣.០៧៣ | ៨.៥៤៥ |
| ប្រាក់កក់ដែលអាចទទួលបានមកវិញ | | ៥២២.៩៥០ | ២.០៩៧ | ៥១៦.២០០ | ២.០៧៨ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ២៤៣.៥២១.៩២៦ | ៩៧៦.៥២៣ | ២២៨.៥៦៨.៨២៥ | ៩១៩.៩៩០ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| ឥណទានផ្តល់ឱ្យភាគីពាក់ព័ន្ធ | ៧ | ៣៨៦.១៩៩.៥១៣ | ១.៥៤៨.៦៦០ | ៣៨៦.១៩៩.៥១៣ | ១.៥៥៤.៤៥៣ |
| ចំណាយបង់មុន និងប្រាក់កក់ | | ១.០០០.២៤០ | ៤.០១១ | ១.៦២៩.៧៩២ | ៦.៥៦០ |
| សន្និធិ | | ១.១១០.៣៩០ | ៤.៤៥៣ | ៦០១.៨៨៧ | ២.៤២៣ |
| ទឹកប្រាក់ត្រូវទទួលពីភាគីពាក់ព័ន្ធ | | ៤១៦.៣៣៩ | ១.៦៧០ | ២១១.៣០៧ | ៨៥១ |
| គណនីអតិថិជនពាណិជ្ជ និងគណនីត្រូវទទួល ផ្សេងៗ | | ៣.៤១២.៩៧៥ | ១៣.៦៨៦ | ៣.៨៥៦.១៨៩ | ១៥.៥២១ |
| ប្រាក់បញ្ញើមានកាលកំណត់ | | - | | ១.៤៧០.៣៥៨ | ៥.៩១៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨ | ២៤.០៤៧.៨២១ | ៩៦.៤៣២ | ៣៧.០៧៩.៦៣៦ | ១៤៩.២៤៦ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ៤១៦.១៨៧.២៧៨ | ១.៦៦៨.៩១២ | ៤៣១.០៤៨.៦៨២ | ១.៧៣៤.៩៧២ |
| **ទ្រព្យសកម្មសរុប** | | ៦៥៩.៧០៩.២០៤ | ២.៦៤៥.៤៣៥ | ៦៥៩.៦១៧.៥០៧ | ២.៦៥៤.៩៦២ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | | ១៤៦.៩៤៥.៣៤០ | ៥៨៩.២៥១ | ១៤៦.៩៤៥.៣៤០ | ៥៩១.៤៥៥ |
| បុព្វលាភភាគហ៊ុន | | ២.៥៥៣.៩០៧ | ១០.២៤១ | ២.៥៥៣.៩០៧ | ១០.២៧៩ |
| ចំណេញរក្សាទុក | | ១៥២.៥៩៤.៦០៨ | ៦១៧.៦៨៦ | ១៤៨.១១០.៩៨៦ | ៥៩៩.៧០១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៥.៧៨២) | - | (៣.៥៥៤) |
| **មូលធនសរុប** | | ៣០២.០៩៣.៨៥៥ | ១.២១១.៣៩៦ | ២៩៧.៦១០.២៣៣ | ១.១៩៧.៨៨១ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| បំណុលភតិសន្យា | | ៣៩.៦២៥.៨២៨ | ១៥៨.៩០០ | ៣៦.៨២២.៧៧៤ | ១៤៨.២១២ |
| បំណុលពន្ធពន្យារ-សុទ្ធ | | ៧.៥៥២.១៣០ | ៣០.២៨៤ | ៨.២៩៨.៥៧៨ | ៣៣.៤០២ |
| ប្រាក់កម្ចី | ៩ | ១៦២.៦០២.៤៣៦ | ៦៥២.០៣៦ | ១៦៨.១៧៥.៤៧៨ | ៦៧៦.៩០៦ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | | ៦៨៧.៥៥១ | ២.៧៥៧ | ៩១៨.០២៤ | ៣.៦៩៥ |
| មូលបត្របំណុល | | ១៨.២៧១.៥១១ | ៧៣.២៦៩ | ១៩.៥១៦.៧៧១ | ៧៨.៥៥៥ |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់ អតីតភាពការងារ | | ៤៤៨.៤៥៧ | ១.៧៩៨ | ៤៧៤.០២៦ | ១.៩០៨ |
| **បំណុលរយៈពេលវែងសរុប** | | ២២៩.១៨៧.៩១៣ | ៩១៩.០៤៤ | ២៣៤.២០៥.៦៥១ | ៩៤២.៦៧៨ |

**ក្រុមហ៊ុន ខេម ជីអេសអេម ម.ក**

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល
## គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

| | | មិនបានធ្វើសវនកម្ម | | បានធ្វើសវនកម្ម | |
|---|---|---|---|---|---|
| | កំណត់ | ៣០ មិថុនា ២០២៥ | | ៣១ ធ្នូ ២០២៤ | |
| | សម្គាល់ | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល |
| **បំណុលរយៈពេលខ្លី** | | | | | |
| បំណុលភតិសន្យា | | ១៣.៦៦៩.៨៩៦ | ៥៤.៨១៦ | ១២.៥៥៧.៦១៤ | ៥០.៥៤៤ |
| បំណុលកិច្ចសន្យា | | ២៥.៩៤៦.៥៤៥ | ១០៤.០៤៦ | ២៦.៤២៨.៦៩១ | ១០៦.៣៧៥ |
| បំណុលបង្គរ | | ៤៨.៣៩៥.២៧៤ | ១៩៤.០៦៥ | ៥១.២០៩.៨៦៣ | ២០៦.១២០ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | | ១.៦១២.២០៥ | ៦.៤៦៥ | ២.៨៦៧.៤២៩ | ១១.៥៤១ |
| ប្រាក់កម្ចី | ៩ | ១៣.៩០៤.០២៥ | ៥៥.៧៥៥ | ១៤.៥៦២.០១៥ | ៥៨.៦១២ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | | ៣១១.៣០៣ | ១.២៤៨ | ៣០១.២២៩ | ១.២១២ |
| មូលបត្របំណុល | | ១.៣៧៥.០៩៣ | ៥.៥១៤ | ១៥៣.៧៨៨ | ៦១៩ |
| កាតព្វកិច្ចទូទាត់ប្រាក់បំណាច់អតីតភាពការងារ | | ១៤.២២២ | ៥៨ | ១៥.២៦៤ | ៦៤ |
| ទឹកប្រាក់ត្រូវទូទាត់ទៅភាគីពាក់ព័ន្ធ | | ៣.៨២៩.០៥៥ | ១៥.៣៥៥ | ២.៧៩៣.៨៩៣ | ១១.២៤៥ |
| ទឹកប្រាក់ត្រូវទូទាត់សម្រាប់ការទិញទ្រព្យសកម្ម | | ៦.៥៦៤.៥៣១ | ២៦.៣២៤ | ៤.៤០៥.១១១ | ១៧.៧៣១ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជ និងគណនីត្រូវទូទាត់ផ្សេងៗ | | ១២.៨០៥.២៨៧ | ៥១.៣៤៩ | ១២.៥០៦.៧២៦ | ៥០.៣៤០ |
| **បំណុលរយៈពេលខ្លីសរុប** | | ១២៨.៤២៧.៤៣៦ | ៥១៤.៩៩៥ | ១២៧.៨០១.៦២៣ | ៥១៤.៤០៣ |
| **បំណុលសរុប** | | ៣៥៧.៦១៥.៣៤៩ | ១.៤៣៤.០៣៩ | ៣៦២.០០៧.២៧៤ | ១.៤៥៧.០៨១ |
| **មូលធន និងបំណុលសរុប** | | ៦៥៩.៧០៩.២០៤ | ២.៦៤៥.៤៣៥ | ៦៥៩.៦១៧.៥០៧ | ២.៦៥៤.៩៦២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលនេះ។

ក្រុមហ៊ុន ខេម ជីអេសអេម ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួមចន្លោះពេល
## សម្រាប់រយៈពេល ៣ខែ និង ៦ខែ បញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

| | | មិនបានធ្វើសវនកម្ម | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | សម្រាប់រយៈពេល ៣ខែ ដែលបានបញ្ចប់ | | | | សម្រាប់រយៈពេល ៦ខែ ដែលបានបញ្ចប់ | | | |
| | កំណត់ | ៣០ មិថុនា ២០២៥ | | ៣០ មិថុនា ២០២៤ | | ៣០ មិថុនា ២០២៥ | | ៣០ មិថុនា ២០២៤ | |
| | សម្គាល់ | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល |
| ចំណូល | | ៤៣.២៦៦.៥៤៧ | ១៧៣.២៨៣ | ៤៣.៧៨៣.០៨៤ | ១៧៨.៦៣៥ | ៨៤.៧០៤.៩៩២ | ៣៣៩.៧៥២ | ៨៦.៨៦៥.០២៩ | ៣៥៣.៩៧៥ |
| **ចំណាយប្រតិបត្តិការ** | | | | | | | | | |
| ចំណាយប្រតិបត្តិការផ្សេងៗ | ១០ | (២០.៤៦៥.១១៧) | (៨១.៩៦៣) | (១៨.៧៥១.០៩៤) | (៧៦.៥០៤) | (៤១.១៨៥.៦២៦) | (១៦៥.១៩៦) | (៣៨.០៧៥.៨២២) | (១៥៥.១៥៩) |
| រំលស់ | | (៨.៣២៥.២០៥) | (៣៣.៣៤២) | (៨.៩៣០.៤៥១) | (៣៦.៤៣៦) | (១៦.៦៤៤.៧៦៩) | (៦៦.៧៦២) | (១៨.៧០៧.០៧៧) | (៧៦.២៣១) |
| ចំណាយបុគ្គលិក | | (៣.៤៧៧.២៧៩) | (១៣.៩២៧) | (៣.៦៩៣.៤៥៥) | (១៥.០៦៩) | (៧.៨២៧.៥៨៨) | (៣១.៣៩៦) | (៥.១០២.២៩៨) | (២០.៧៩២) |
| ចំណាយភ្ជាប់បណ្តាញទូរស័ព្ទឆ្លងប្រព័ន្ធ | | (៤៨៦.៩៥៥) | (១.៩៥០) | (៧៩៤.៦៤៤) | (៣.២៤២) | (៩៨១.១៧០) | (៣.៩៣៥) | (១.៥៥១.៣១១) | (៦.៣២២) |
| (ខាត)/ចំណេញផ្សេងៗ – សុទ្ធ | ១១ | (៥.២៦៩) | (២១) | (២៥.១៣៦) | (១០៣) | (៣៧.៩៤៩) | (១៥២) | ៤.៩៩៣.១២៧ | ២០.៣៤៧ |
